# គោលការណ៍ពីរយ៉ាងសំរាប់សេដ្ឋកិច្ច

ប្រធាន ឌៀថើរ អេស្វ អុជដូហ្វ
ទីប្រឹក្សាទីពីរនៅក្នុងគណៈប្រធានទីមួយ

*ជាញឹកញាប់ ការស្ថិតនៅក្នុងការសាកល្បងនៃទុក្ខវេទនា បានធ្វើឱ្យយើងរៀនទូវមេរៀនដ៏សំខាន់ជាច្រើន ដែលជួយរៀបចំអាកប្ប-កិរិយា និងជោគវាសនារបស់យើង ។*

ក្នុងដំណើរទស្សនកិច្ចជាច្រើនរបស់យើងទៅជួបនឹងសមាជិកសាសនាចក្រនៅជុំវិញពិភពលោក និងតាមរយៈមធ្យោបាយនៃការបង្កើតបណ្តាញបញ្ជូនភាព នោះយើងបានទទួលព័ត៌មានត្រឡប់យ៉ាងលឿនស្តីអំពីស្ថានភាព និងឧបសគ្គរបស់សមាជិកយើង ។ មានសមាជិករបស់យើងជាច្រើនបានរងឥទ្ធិពលពីគ្រោះមហន្តរាយនៅជុំវិញពិភពលោកទាំងរឿងធម្មជាតិ និងរឿងដែលមនុស្សបង្កឡើង ។ យើងក៏បានយល់ដឹងផងដែរថា មានគ្រួសារជាច្រើនត្រូវកាត់បន្ថយការចំណាយ និងមានការព្រួយបារម្ភចំពោះការស៊ូទ្រាំនឹងគ្រាដ៏លំបាកទាំងនេះ ។

បងប្អូនប្រុសទាំងឡាយ យើងយល់ពីអារម្មណ៍របស់អ្នករាល់គ្នា ។ យើងស្រឡាញ់អ្នករាល់គ្នា ហើយយើងនឹងធ្វើការអធិស្ឋានឱ្យអ្នក ។ នៅក្នុងឆាកជីវិតរបស់ខ្ញុំ ខ្ញុំធ្លាប់ជួបនឹងគ្រាដ៏រីករាយ និងគ្រាដ៏លំបាកល្មមគ្រប់គ្រាន់ ដើម្បីដឹងថា គ្រាដ៏លំបាកនឹងបើកផ្លូវឱ្យមានភាពកក់ក្តៅ និងសេចក្តីសង្ឃឹមនៃគ្រាដ៏ប្រសើរមួយជាពុំខានឡើយ ។ ខ្ញុំមានជំនឿចិត្តខ្លាំងណាស់ចំពោះអនាគត ។ បងប្អូនប្រុសទាំងឡាយ ចំពោះអ្វីដែលយើងត្រូវធ្វើ គឺយើងត្រូវបន្តមានភាពខ្ជាប់ខ្ជួននៅក្នុងសេចក្តីសង្ឃឹម ធ្វើការឱ្យអស់ពីកម្លាំងរបស់យើង និងទុកចិត្តលើព្រះ ។

ថ្មីៗនេះ ខ្ញុំបានគិតពីគ្រាមួយនៅក្នុងជីវិតរបស់ខ្ញុំ ខណៈដែលទម្ងន់នៃការព្រួយបារម្ភ និងការខ្វាយខ្វល់ចំពោះអនាគតជាក់លាក់ហាក់ដូចជាកើតមានជាប់ជានិច្ចនោះ ។ កាលនោះ ខ្ញុំមានអាយុ 11 ឆ្នាំ ហើយបានរស់នៅជាមួយនឹងគ្រួសាររបស់ខ្ញុំក្នុងបន្ទប់តូចមួយនៃកសិដ្ឋានរបស់យើងក្បែរទីក្រុងហ្វ្រែងហ្វឺត ប្រទេសអាល្លឺម៉ង់ ។ យើងបានភៀសខ្លួនជាលើកទីពីរ នៅក្នុងរយៈពេលតែប៉ុន្មានឆ្នាំប៉ុណ្ណោះ ហើយបានជួបនឹងការលំបាកក្នុងការសំរបខ្លួនរបស់យើងនៅទីកន្លែងថ្មីមួយដែលមានចម្ងាយយ៉ាងឆ្ងាយពីផ្ទះរបស់យើងកាលពីមុន ។ ខ្ញុំអាចនិយាយបានថា យើងគឺជាមនុស្សក្រីក្រ បើនិយាយពីបញ្ហានោះ គឺវានិយាយមិនចេះចប់នោះទេ ។ យើងទាំងអស់គ្នាបានដេកនៅក្នុងបន្ទប់ដ៏តូចមួយ ដែលស្ទើរតែរកផ្លូវដើរនៅជុំវិញគ្រែដេកសឹងតែមិនបានផង ។ នៅក្នុងបន្ទប់តូចមួយផ្សេងទៀត យើងមានបំណែកគ្រឿងសង្ហារឹមមួយចំនួន និងចង្ក្រានមួយដែលអ្នកម្តាយរបស់ខ្ញុំប្រើដើម្បីចំអិនម្ហូប ។ ដើម្បីឆ្លងពីបន្ទប់មួយទៅបន្ទប់មួយទៀត នោះយើងត្រូវឆ្លងកាត់កន្លែងដាក់ឧបករណ៍ និងប្រដាប់ប្រដារ សាច់ចំរុះ និងសាច់ក្រកដែលដាក់ព្យួរនៅលើធ្នឹម ។ ក្លិនរបស់សាច់ទាំងនោះតែងតែធ្វើឱ្យខ្ញុំឃ្លានជានិច្ច ។ យើងគ្មានបន្ទប់ទឹកនោះទេ មានតែបន្ទប់អនាម័យនៅខាងក្រៅផ្ទះ---មានចម្ងាយដល់ទៅ 15 ម៉ែត្រ---តែនៅរដូវរងារបន្ទប់នេះហាក់ដូចជាមានចម្ងាយឆ្ងាយជាងនេះទៅទៀត ។

ដោយសារខ្ញុំជាអ្នកភៀសខ្លួន ហើយសម្លេងជាពួកអាល្លឺម៉ង់ខាងកើត នោះជាញឹកញាប់ក្មេងដទៃទៀតបានសើចចំអកឱ្យខ្ញុំ ហើយបានដាក់ងារដែលធ្វើឱ្យខ្ញុំមានការឈឺចាប់យ៉ាងខ្លាំង ។ នៅក្នុងភាពជាយុវវ័យរបស់ខ្ញុំ ខ្ញុំជឿថា នេះគឺជាគ្រាមួយដែលបានធ្វើឱ្យខ្ញុំបាក់ទឹកចិត្តបំផុត ។

ឥឡូវនេះ ខ្ញុំអាចក្រឡេកមើលទៅពេលវេលាទាំងនោះ ដោយមានការយល់ដឹងដែលកើតពីបទពិសោធន៍ជាច្រើនទសវត្សរ៍។ ទោះជាខ្ញុំនៅចងចាំពីការឈឺចាប់ និងការអស់សង្ឃឹមទាំងនោះក្តី ក៏ឥឡូវនេះខ្ញុំអាចមើលឃើញនូវរឿងដែលខ្ញុំមិនអាចមើលឃើញនៅពេលនោះ : នេះគឺជាគ្រានៃការរីកចំរើនដ៏អស្ចារ្យមួយសំរាប់ខ្លួនខ្ញុំ។ នៅក្នុងពេលនេះ គ្រួសាររបស់យើងត្រូវបានផ្សារភ្ជាប់ជាមួយនឹងគ្នា។ ខ្ញុំបានមើល ហើយបានរៀនពីឪពុកម្តាយរបស់ខ្ញុំ។ ខ្ញុំមានការកោតសរសើរចំពោះការតាំងចិត្ត និងភាពសុទិដ្ឋិនិយមរបស់ពួកគាត់។ ខ្ញុំបានរៀនពីពួកគាត់ថា ការយកឈ្នះលើទុក្ខវេទនាអាចកើតឡើងបាន នៅពេលប្រឈមមុខដោយមានសេចក្តីជំនឿ សេចក្តីក្លាហាន និងសេចក្តីតស៊ូព្យាយាមនោះ។

ដោយដឹងថា អ្នករាល់គ្នាមួយចំនួនកំពុងជួបប្រទះនូវគ្រានៃការព្រួយបារម្ភ និងការអស់សង្ឃឹម ដូច្នេះនៅថ្ងៃនេះ ខ្ញុំចង់លើកឡើងពីគោលការណ៍សំខាន់ពីរយ៉ាង ដែលបានជួយជំរុញខ្ញុំរហូតមកដល់គ្រាដ៏ជោគជ័យនេះក្នុងឆាកជីវិតរបស់ខ្ញុំ។

## គោលការណ៍ទីមួយ : ការងារ

រហូតមកទល់សព្វថ្ងៃនេះ ខ្ញុំមានការស្ងើចសរសើរជាខ្លាំងពីរបៀបដែលគ្រួសាររបស់ខ្ញុំបានខិតខំធ្វើការ បន្ទាប់ពីបានបាត់បង់អ្វីៗគ្រប់យ៉ាងក្រោយពីសង្គ្រាមលោកលើកទីពីរ! ខ្ញុំចាំបានថា ឪពុករបស់ខ្ញុំ---ជាពលរដ្ឋសាមញ្ញម្នាក់ដែលមានការអប់រំ និងបទពិសោធន៍ធម្មតា---បានប្រឡូកក្នុងការងារដ៏លំបាកៗមួយចំនួន ដូចជា កម្មកររ៉ែធ្យូង កម្មករអណ្តូងរ៉ែអ៊ុយរ៉ានីញ៉ូម ជាងម៉ាស៊ីន និងអ្នកបើករថយន្តដឹកឥវ៉ាន់។ គាត់បានចេញពីផ្ទះតាំងពីព្រលឹមស្រាងៗ ហើយជាញឹកញាប់ត្រឡប់មកផ្ទះវិញយប់ជ្រៅ ដើម្បីផ្គត់ផ្គង់ដល់គ្រួសារ។ អ្នកម្តាយរបស់ខ្ញុំបានចាប់ផ្តើមមុខរបរបោកសំលៀកបំពាក់ ហើយត្រូវធ្វើការច្រើនម៉ោង តែទទួលបានប្រាក់កំរៃពេលកម្មតិច។ គាត់បានបញ្ចូលបងស្រីរបស់ខ្ញុំ ហើយនឹងរូបខ្ញុំឱ្យធ្វើការជាមួយគាត់ផងដែរ។ ដោយខ្ញុំមានកង់មួយ នោះខ្ញុំបានក្លាយជាអ្នកដឹកជញ្ជូនខោអាវ។ ខ្ញុំបានមានអារម្មណ៍ល្អដោយមានលទ្ធភាពជួយបន្តិចបន្តួចដល់គ្រួសាររបស់ខ្ញុំ ហើយការងារដោយប្រើកម្លាំងនេះក៏បានក្លាយជាពរជ័យមួយចំពោះសុខភាពរបស់ខ្ញុំដែរ តែនៅពេលនោះខ្ញុំមិនបានដឹងឡើយ។

វាពុំមែនជាការងាយស្រួលនោះឡើយ ប៉ុន្តែការងារជួយយើងកុំឱ្យគិតច្រើនពីការលំបាកនៃស្ថានភាពរបស់យើង។ ទោះជាស្ថានភាពរបស់យើងមិនផ្លាស់ប្តូរភ្លាមៗក៏ដោយ តែវាពិតជាមានការផ្លាស់ប្តូរ។ នោះគឺជារឿងដែលទាក់ទងនឹងការងារ។ បើយើងព្យាយាមធ្វើការតាមធម្មតា---ដោយចេះប្រមាណ និងខ្ជាប់ខ្ជួន---នោះរឿងទាំងឡាយនឹងមានភាពប្រសើរឡើងជាប្រាកដ។

ខ្ញុំមានការកោតសរសើរខ្លាំងណាស់ដល់បុរសស្ត្រី និងកុមារទាំងឡាយដែលស្គាល់ពីរបៀបធ្វើការងារ! ព្រះអម្ចាស់ស្រឡាញ់ពួកអ្នកធ្វើការខ្លាំងណាស់! ទ្រង់បានមានបន្ទូលថា "ឯងនឹងបានអាហារស៊ីដោយការបែកញើស"[1] ហើយ "អ្នកដែលធ្វើការនោះគួរនឹងបានឈ្នួលរបស់ខ្លួនហើយ"។[2] ទ្រង់ក៏ប្រទានការសន្យាមួយផងដែរថា : "ចូរលូកកណ្តៀវរបស់អ្នក ដោយអស់ពីព្រលឹងរបស់អ្នក ហើយបាបទាំងឡាយរបស់អ្នកត្រូវបានអត់ទោសឱ្យហើយ"។[3] អស់អ្នកណាដែលពុំភ័យខ្លាចចំពោះការងារ ហើយផ្តោតសំខាន់ទៅលើការសំរេចបាននូវគោលដៅដ៏សំខាន់នោះ គឺជាពរជ័យមួយចំពោះក្រុមគ្រួសារ សហគមន៍ ប្រទេសជាតិ និងសាសនាចក្ររបស់ពួកគេហើយ។

ព្រះអម្ចាស់មិនបានរំពឹងទុកឱ្យយើងធ្វើការងារដែលហួសពីសមត្ថភាពរបស់យើងនោះទេ។ ទ្រង់មិនបាន (ហើយយើងក៏មិនត្រូវ) ប្រៀបធៀបកិច្ចការរបស់យើងទៅនឹងកិច្ចការរបស់អ្នកដទៃនោះទេ។ ព្រះវរបិតាសួគ៌របស់យើងបានសុំតែម្យ៉ាងប៉ុណ្ណោះគឺថា ឱ្យយើងធ្វើឱ្យអស់ពីលទ្ធភាព---ឱ្យយើងធ្វើការស្របទៅតាមសមត្ថភាពដ៏ពេញលេញរបស់យើង ទោះជាកិច្ចការនោះធំ ឬតូចក្តី។

ការងារ គឺជាថ្នាំបន្សាបសំរាប់ការព្រួយបារម្ភ ជាឥទ្ធិពលនៃការព្យាបាលទុក្ខសោក និងជាច្រកទ្វារឆ្ពោះទៅរកឱកាសល្អៗ។ បងប្អូនប្រុសជាទីស្រឡាញ់របស់ខ្ញុំ ទោះជាស្ថានភាពជីវិតរបស់យើងបែបណាក្តី ចូរយើងធ្វើឱ្យអស់ពីលទ្ធភាព ហើយអភិវឌ្ឍកេរ្តិ៍ឈ្មោះដ៏ល្អបំផុតមួយនៅរាល់កិច្ចការដែលយើងធ្វើ។ ចូរយើងផ្តុំគំនិត និងរូបកាយរបស់យើងចំពោះឱកាសដ៏រុងរឿង ដើម្បីការងារដែលកើតមានជារៀងរាល់ថ្ងៃ។

នៅពេលរទេះយើងជាប់ផុងនៅក្នុងភក់ នោះព្រះមានព្រះទ័យចាំជួយដល់អ្នកដែលចេញមកខាងក្រៅដើម្បីរុញរទេះនោះ ជាជាងអ្នកដែលគ្រាន់តែធ្វើការអធិស្ឋានរបស់ខ្លួននោះ---ទោះជាប្រសប់និយាយយ៉ាងណាក៏ដោយ។ ប្រធាន ថូម៉ាស អេស ម៉នសុន បានលើកឡើងពីការងារតាមរបៀបនេះថា ៖ "ការចង់ធ្វើការងារ និងការនិយាយថា យើងនឹងខិតខំធ្វើការ គឺវាពុំគ្រប់គ្រាន់នោះទេ…។ ដើម្បីសំរេចគោលដៅរបស់យើងបាន វាទាមទារឱ្យមានការអនុវត្តន៍ ពុំមែនការគិតតែម្យ៉ាងនោះទេ។ ជាញឹកញាប់ បើយើងផ្អាកធ្វើការងារដើម្បីឆ្ពោះទៅរកគោលដៅរបស់យើង នោះយើងនឹងមិនបានពីការសំរេចគោលដៅទាំងនោះឡើយ"។4

ការងារអាចក្លាយទៅជាការតំឡើងឋានៈ និងជោគជ័យ ប៉ុន្តែសូមចងចាំពីការព្រមានរបស់យ៉ាកុបថា កុំ "ចំណាយ [កម្លាំងរបស់អ្នក] សំរាប់អ្វីដែលពុំអាចធ្វើឱ្យបានស្កប់ស្កល់ឡើយ"។5 បើយើងលះបង់ខ្លួនឯងដើម្បីទទួលបានទ្រព្យសម្បត្តិខាងលោកិយ និងភាពល្បីល្បាញនៃការទទួលស្គាល់ជាសាធារណៈ ដោយបោះបង់គ្រួសាររបស់យើង និងការរីកចំរើនខាងវិញ្ញាណរបស់យើងចោល នោះមិនយូរប៉ុន្មានឡើយ យើងនឹងរកឃើញថា យើងបានធ្វើការលះបង់ដោយឥតប្រយោជន៍។ ការងារសុចរិតដែលយើងធ្វើនៅក្នុងរង្វង់គ្រួសារ គឺជារឿងដ៏ពិសិដ្ឋបំផុត។ អត្ថប្រយោជន៍របស់វា គឺមានដ៏នៅអស់កល្បជានិច្ច។ វាមិនអាចធ្វើការចែករំលែកបានឡើយ។ វាគឺជាគ្រឹះនៃការងាររបស់យើង ក្នុងនាមជាពួកអ្នកកាន់បព្វជិតភាព។

សូមចងចាំថា នៅក្នុងពិភពលោកនេះ យើងគ្រាន់តែជាអ្នកដំណើរបណ្តោះអាសន្នប៉ុណ្ណោះ។ ចូរយើងកុំលះបង់ទេពកោសល្យ និងកម្លាំងដែលព្រះប្រទានឱ្យ ដើម្បីប្រមូលយកតែទ្រព្យសម្បត្តិ និងការសរសើរនៅលើផែនដីនេះឡើយ តែផ្ទុយទៅវិញ ចូរយើងចំណាយពេលវេលារបស់យើងដើម្បីធ្វើឱ្យជីវភាពខាងវិញ្ញាណរបស់យើងមានការរីកចំរើន។ ត្បិត ក្នុងនាមជាបុត្រានៃព្រះដ៏ខ្ពស់បំផុត នោះយើងត្រូវបានបង្កើតឡើង ដើម្បីស្វែងរកបទពិសោធន៍ដ៏មហិមា។

ឥឡូវនេះ បងប្អូនប្រុសដែលមានវ័យចំណាស់ មានពាក្យឃ្លាសំរាប់យើងទាំងអស់គ្នាថា៖ ការចូលនិវត្តន៍ពុំមែនជាផ្នែកមួយនៃផែនការសុភមង្គលរបស់ព្រះអម្ចាស់ឡើយ។ នៅក្នុងការទទួលខុសត្រូវបព្វជិតភាព គឺគ្មានថ្ងៃសំរាក ឬកម្មវិធីចូលនិវត្តន៍នោះទេ---ដោយមិនគិតពីអាយុ ឬកាយសម្បទាឡើយ។ ខណៈដែលការពោលពាក្យថា "ខ្ញុំធ្លាប់ធ្វើកិច្ចការនេះរួចហើយ" អាចជាការដោះសារមួយដ៏ល្អ ដើម្បីជៀសវាងពីការលេងកីឡាអិល បដិសេធពីការបបួលជិះម៉ូតូ ឬជៀសវាងពីសម្លការីហិលនៅពេលបរិភោគអាហារប៊ូហ្វេបាន តែវាពុំមែនជាការដោះសារមួយដែលអាចទទួលយកបានឡើយ ដើម្បីជៀសវាងពីការទទួលខុសត្រូវដែលបានចុះសេចក្តីសញ្ញាថានឹងញែកពេលវេលា ទេពកោសល្យ និងធនធានការងាររបស់យើងឱ្យបរិសុទ្ធក្នុងកិច្ចការនៃនគរព្រះ។

បន្ទាប់ពីបានបំរើនៅក្នុងសាសនាចក្រអស់រយៈពេលជាច្រើនឆ្នាំ ប្រហែលមានមនុស្សមួយចំនួនជឿថា ពួកគេអាចសំរាកបានហើយ ហើយទុកឱ្យអ្នកដទៃទៀតធ្វើវិញម្តង។ បងប្អូនប្រុសទាំងឡាយ បើនិយាយឱ្យចំទៅ ការគិតបែបនេះ គឺមិនសក្តិសមជាសិស្សរបស់ព្រះគ្រីស្ទឡើយ។ ផ្នែកដ៏សំខាន់មួយនៃកិច្ចការរបស់យើងនៅលើផែនដីនេះ គឺដើម្បីស៊ូទ្រាំ---ដោយក្តីរីករាយរហូតដល់ចុងបំផុត---នៅក្នុងជីវិតរស់នៅប្រចាំថ្ងៃរបស់យើង។

ឥឡូវនេះ ក៏មានពាក្យមួយឃ្លាទៀតសំរាប់បងប្អូនប្រុសវ័យក្មេងនៅក្នុងបព្វជិតភាពមិលគីស្សាដែករបស់យើងផងដែរ ដែលកំពុងព្យាយាមសំរេចគោលដៅដ៏ត្រឹមត្រូវ ដើម្បីទទួលបានការអប់រំ និងស្វែងរកកិរិយាដ៏នៅអស់កល្បជានិច្ចម្នាក់។ បងប្អូនប្រុសរបស់ខ្ញុំ គោលដៅទាំងនេះ គឺជារឿងត្រឹមត្រូវណាស់ តែសូមចងចាំថា ៖ ការធ្វើការដោយឧស្សាហ៍ព្យាយាម នៅក្នុងចំការទំពាំងបាយជូរបស់ព្រះអម្ចាស់នឹងជួយបង្កើនឱកាសទទួលបានជោគជ័យ នៅក្នុងគោលដៅដ៏សក្តិសមទាំងពីរនេះ។

មិនថាអ្នករាល់គ្នាជាយុវជនថ្នាក់ឌីកុន ឬជាបុរសចំណាស់ក្នុងថ្នាក់សង្ឃជាន់ខ្ពស់នោះទេ គឺមានកិច្ចការដែលត្រូវធ្វើដូចគ្នា!

**គោលការណ៍ទីពីរ ៖ រៀនសូត្រ**

នៅគ្រានៃវិបត្តិសេដ្ឋកិច្ចក្រោយសង្គ្រាមរបស់អាល្លឺម៉ង់ នោះឱកាសសំរាប់ការអប់រំ គឺពុំមានច្រើនដូចយើងសព្វថ្ងៃនេះឡើយ។ ប៉ុន្តែទោះជាមានជំរើសពុំច្រើនក្តី ក៏ខ្ញុំតែងតែមានអារម្មណ៍ស្រេកឃ្លានចំពោះការរៀនសូត្រជានិច្ច។ ខ្ញុំនៅចាំថា មានថ្ងៃមួយពេលដែលខ្ញុំបានយកកង់ចេញដើម្បីដឹកជញ្ជូនសំលៀកបំពាក់ នោះខ្ញុំបានចូលទៅផ្ទះរបស់មិត្តរួមថ្នាក់ខ្ញុំម្នាក់។ នៅក្នុងបន្ទប់មួយ មានដាក់តុតូចចំនួនពីរទល់នឹងជញ្ជាំង។ នេះគឺជាទិដ្ឋភាពដ៏អស្ចារ្យខ្លាំងណាស់! ក្មេងទាំងនោះមានសំណាងអ្វីម្ល៉េះទេ ដោយមានតុរៀនផ្ទាល់ខ្លួននោះ! ខ្ញុំបានស្រមើស្រមៃឃើញថា ពួកគេកំពុងអង្គុយនៅទីនេះដោយបើកសៀវភៅសិក្សាមេរៀន និងធ្វើកិច្ចការសាលារបស់ពួកគេ។ ខ្ញុំបានមានអារម្មណ៍ថា ការមានតុផ្ទាល់ខ្លួនគឺជារឿងដ៏អស្ចារ្យបំផុតមួយនៅក្នុងពិភពលោកនេះ។

ខ្ញុំត្រូវរង់ចាំយ៉ាងយូរ ពីមុនបំណងប្រាថ្នានោះបានសំរេច។ ជាច្រើនឆ្នាំក្រោយមក ខ្ញុំបានមានការងារមួយក្នុងស្ថាប័នស្រាវជ្រាវដែលមានបណ្ណាល័យដ៏ធំ។ ខ្ញុំនៅចាំបានពីការចំណាយពេលទំនេររបស់ខ្ញុំជាច្រើន នៅក្នុងបណ្ណាល័យនោះ។ នៅទីបំផុត ខ្ញុំអាចមានតុអង្គុយ---តែម្នាក់ឯង---ហើយអានពីព័ត៌មាន និងចំណេះដឹងដែលសៀវភៅទាំងឡាយបានផ្តល់ឱ្យ។ ខ្ញុំចូលចិត្តអានសៀវភៅ និងការរៀនសូត្រខ្លាំងណាស់! នៅពេលនោះ ខ្ញុំបានចាប់ផ្តើមយល់ពីពាក្យចាស់លោកពេលថា ៖ ការអប់រំពុំមែនគ្រាន់តែជាការចាក់បំពេញធុងឱ្យបានច្រើននោះទេ ប៉ុន្តែវាគឺជាការដុតបំភ្លឺភ្លើងវិញ"។

ចំពោះសមាជិកសាសនាចក្រ ការអប់រំពុំមែនគ្រាន់តែជាគំនិតដ៏ល្អប៉ុណ្ណោះទេ---វាគឺជាព្រះបញ្ញត្តិ។ យើងត្រូវតែរៀន "អំពីរបស់ទាំងឡាយនៅលើទាំងស្ថានសួគ៌ និងនៅលើផែនដី និងនៅក្រោមផែនដីផង របស់ទាំងឡាយដែលធ្លាប់មានមក របស់ទាំងឡាយដែលមានពេលនេះ របស់ទាំងឡាយដែលនឹងកើតឡើងនៅពេលឆាប់ៗ របស់ទាំងឡាយដែលនៅក្នុងផ្ទះ របស់ទាំងឡាយនៅស្រុកផ្សេង" ។6

យ៉ូសែប ស្ម៊ីធ ស្រឡាញ់ការរៀនសូត្រណាស់ ទោះជាលោកមានឱកាសតិចតួចសំរាប់ការអប់រំទូទៅក៏ដោយ ។ នៅក្នុងសៀវភៅកំណត់ហេតុរបស់លោក លោកបានមានប្រសាសន៍យ៉ាងរីករាយអំពីពេលវេលាដែលបានចំណាយនៅក្នុងការសិក្សា ហើយជាញឹក-ញាប់លោកបានសម្ដែងចេញនូវសេចក្ដីស្រឡាញ់ចំពោះការរៀនសូត្ររបស់លោក ។7

យ៉ូសែប បានបង្រៀនពួកបរិសុទ្ធថា ចំណេះដឹងគឺជាផ្នែកដ៏ចាំបាច់មួយនៃជីវិតរមែងស្លាប់របស់យើង ត្បិត "មនុស្សម្នាក់នឹងត្រូវបានសង្គ្រោះ ដរាបណាគាត់បាន[ទទួល]ចំណេះដឹង"8 ហើយថា "គោលការណ៍បញ្ញាណាក៏ដោយ ដែលយើងបាននៅក្នុងជីវិតនេះ នោះនឹងនៅជាប់នឹងយើងក្នុងដំណើររស់ឡើងវិញ" ។9 នៅក្នុងគ្រាដ៏លំបាក ការរៀនសូត្រគឺមានសារៈសំខាន់កាន់តែខ្លាំងថែមទៀត ។ ព្យាការី យ៉ូសែប បានបង្រៀនថា "ចំណេះដឹងអាចលុបបំបាត់សេចក្ដីងងឹត [ការព្រួយបារម្ភ] និងការសង្ស័យបាន ត្បិតការណ៍ទាំងនេះមិនអាចកើតឡើងនៅទីកន្លែងដែលមានចំណេះដឹងបានឡើយ" ។10

បងប្អូនប្រុសទាំងឡាយ អ្នករាល់គ្នាមានកាតព្វកិច្ចមួយ ដើម្បីរៀនសូត្រឱ្យបានច្រើនទៅតាមលទ្ធភាពរបស់អ្នក ។ សូមលើកទឹកចិត្តក្រុមគ្រួសាររបស់អ្នក សមាជិកក្រុមរបស់អ្នក និងមនុស្សគ្រប់គ្នាឱ្យរៀនសូត្រ ហើយក្លាយជាមនុស្សដែលមានការអប់រំដ៏ប្រសើរ ។ បើជំរើសសំរាប់ការអប់រំទូទៅពុំអាចកើតមានឡើង សូមកុំបណ្ដោយឱ្យការណ៍នោះរារាំងអ្នកពីការទទួលបាននូវរាល់ចំណេះដឹងដែលអ្នករាល់គ្នាអាចធ្វើបានឡើយ ។ ជាទូទៅ នៅក្នុងស្ថានភាពបែបនេះ នោះសៀវភៅល្អៗជាច្រើនអាចក្លាយទៅជា "សាកល-វិទ្យាល័យ"របស់អ្នកបាន---សៀវភៅទាំងឡាយគឺជាថ្នាក់រៀនមួយដែលតែងតែត្រៀមខ្លួនចាំជានិច្ច ហើយវាព្រមទទួលយកអស់អ្នកដែលអនុវត្ត ។ ចូរព្យាយាមបង្កើនចំណេះដឹងរបស់អ្នកអំពីអ្វីគ្រប់យ៉ាងដែលមាន "គុណធម៌ គួរស្រឡាញ់ ឬឈ្មោះល្អ ឬក៏គួរឱ្យសរសើរ" ។11 សូមស្វែងរកចំណេះដឹង "ដោយសារការសិក្សា និងដោយសារសេចក្ដីជំនឿផង" ។12 សូមស្វែងរកដោយវិញ្ញាណរាបសា និងចិត្តទន់ទាប ។13 នៅពេលអ្នករាល់គ្នាអនុវត្តទិដ្ឋភាពនៃសេចក្ដីជំនឿខាងវិញ្ញាណទៅនឹងការសិក្សារបស់អ្នក---ព្រមទាំងជាមួយនឹងការសិក្សារឿងខាងសាច់ឈាមរបស់អ្នកក្ដី---នោះអ្នករាល់គ្នាអាចបង្កើតសមត្ថភាពផ្នែកប្រាជ្ញារបស់អ្នកបាន ត្បិត "បើសិនជាភ្នែករបស់អ្នកស្មោះស្ម័គ្រទាំងស្រុងទៅចំពោះសិរីល្អរបស់ [ព្រះ] នោះរូបកាយរបស់អ្នកទាំងមូលនឹងបានពោរពេញទៅដោយពន្លឺ ហើយនឹង...[យល់ ]គ្រប់ទាំងអស់" ។14

នៅក្នុងការរៀនសូត្ររបស់យើង ចូរយើងកុំបដិសេធនឹងគ្រឹះនៃវិវរណៈ ។ ព្រះគម្ពីរ និងប្រសាសន៍របស់ពួកសាវក និងព្យាការីសម័យបច្ចុប្បន្ន គឺជាប្រភពនៃប្រាជ្ញា ចំណេះដឹងដ៏ទេវភាព និងវិវរណៈផ្ទាល់ខ្លួន ដើម្បីជួយយើងស្វែងរកចម្លើយដោះស្រាយរាល់ឧបសគ្គនៅក្នុងជីវិត ។ ចូរយើងរៀនពីព្រះគ្រីស្ទ ។ ចូរយើងស្វែងរកចំណេះដឹងដែលដឹកនាំទៅរកសេចក្ដីសុខសាន្ដ សេចក្ដីពិត និងអាថ៌កំបាំងដ៏វិសេសវិសាលនៃភាពដ៏នៅអស់កល្បជានិច្ច ។15

## សេចក្ដីសន្និដ្ឋាន

បងប្អូនប្រុសទាំងឡាយ ពេលខ្ញុំគិតត្រឡប់ទៅវិញ កាលពីខ្ញុំមានអាយុ 11 ឆ្នាំ រស់នៅក្នុងទីក្រុងហ្វ្រេងហ្វឺត ប្រទេសអាល្លឺម៉ង់ជាមនុស្សមានការព្រួយបារម្ភចំពោះអនាគតរបស់ខ្លួន ហើយបានទទួលអារម្មណ៍ឈឺចាប់ដ៏នៅអស់កល្បជានិច្ច ដោយសារតែពាក្យ

សម្តីមិនសមរម្យ ។ នៅពេលនេះ ខ្ញុំបានចងចាំដោយជិតជាប់នូវអារម្មណ៍សោកសៅ ។ នៅខណៈនោះ បើខ្ញុំមិនព្រមទទួលយកការសាកល្បង និងឧបសគ្គទាំងនោះទេ នោះខ្ញុំនឹងមិនដឹងថា មេរៀនទាំងឡាយដែលខ្ញុំបានរៀន គឺជារឿងដ៏ចាំបាច់ដើម្បីរៀបចំខ្លួនសំរាប់ឱកាសនាពេលអនាគតនោះឡើយ ។ តែឥឡូវនេះ ជាច្រើនឆ្នាំក្រោយមក ខ្ញុំបានដឹងយ៉ាងច្បាស់ថា : ជាញឹកញាប់ ការស្ថិតនៅក្នុងការសាកល្បងនៃទុក្ខវេទនា បានធ្វើឱ្យយើងរៀននូវមេរៀនដ៏សំខាន់ជាច្រើន ដែលជួយរៀបចំអាកប្បកិរិយា និងជោគ-វាសនារបស់យើង ។

ខ្ញុំសូមអធិស្ឋានថា នៅក្នុងខែ និងឆ្នាំថ្មី នោះយើងអាចបំពេញពេលវេលារបស់យើងជាមួយនឹងកិច្ចការសុចរិត ។ ខ្ញុំសូមអធិស្ឋានថា យើងនឹងរៀនសូត្រ និងកែលំអគំនិត និងដួងចិត្តរបស់យើង តាមរយៈការទទួលទានចេញពីប្រភពនៃសេចក្តីពិតដ៏បរិសុទ្ធ ។ ខ្ញុំសូមបន្សល់ទុកជាមួយនឹងអ្នករាល់គ្នានូវសេចក្តីស្រឡាញ់របស់ខ្ញុំ និងពរជ័យទាំងឡាយនៅក្នុងព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ អាម៉ែន ។

កំណត់ចំណាំ

1. លោកុប្បត្តិ 3:19 ។

2. គ. និង ស. 84:79 ។

3. គ. និង ស. 31:5 ។

4. ថូម៉ាស អេស ម៉នសុន "A Royal Priesthood" *Liahona* ខែ វិច្ឆិកា ឆ្នាំ 2007 ទំព័រ 59 ។

5. នីហ្វៃទី 2 9:51 ។

6. សូមមើល គ. និង ស. 88:79-- 80 ។

7. សូមមើល *Journals: Volume 1:1832-1839* វ៉ុលទី 1 នៃ the Journals series of The Joseph Smith Papers រៀបរៀងដោយ Dean C. Jessee, Ronald K. Esplin, and Richard Lyman Bushman (2008) ទំព័រ 84, 135,164 ។

8. យ៉ូសែប ស្ម៊ីធ នៅក្នុង *History of the Church*, 4:588 ។

9. សូមមើល គ. និង ស.130:18--19 ។

10. Joseph Smith, in *History of the Church* 5:340 ។

11. មាត្រានៃសេចក្តីជំនឿ 1:13 ។

12. គ. និង ស. 109:7 ។

13. សូមមើល គ. និង ស. 136:33 ។

14. គ. និង ស. 88:67

15. សូមមើល គ. និង ស. 42:61 ។